雲南日報
YUNNAN DAILY PRESS GROUP
云南日报报业集团
No.211

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

khmerlight@163.com
yunnangateway.com
Follow *Amazing Yunnan* on Facebook

ឆ្នាំទី28លេខ8149 ថ្ងៃសុក្រ ទី07 ខែកុម្ភៈ ឆ្នាំ2020

## ប្រជាជនគ្រប់ជនជាតិមានជីវភាពរស់នៅកាន់តែល្អប្រសើរ



*នៅថ្ងៃទី១៩ ខែ មករា ឆ្នាំ២០២០ ឯកឧត្តមស៊ី ជីនភីង ប្រធានាធិបតីចិនអញ្ជើញទៅទស្សនាក្រុមជនជាតិវ៉ាផុងចាយស៊ីម៉ូវ៉ា ភូមិសានចាឃុំឈើងស្វយ ស្រុកធឹងឈុង ក្រុងប៉ាវសាន*

អ្នករៀបរៀង:កាលពីថ្ងៃទី ១៩ ដល់ទី២១ខែមករាឆ្នាំ២០២០ ឯកឧត្តមស៊ីជីនភីង អគ្គលេខាធិការបក្សកុម្មុយនិស្ត ចិនប្រធានាធិបតីចិននិងជាប្រធានគណៈកម្មាធិការយោធាមជ្ឈិមបក្សកុម្មុយនិស្តចិនបានអញ្ជើញទៅខេត្តយូនណានដើម្បីសួរសុខទុក្ខជាមួយកម្មាភិបាល និងប្រជាជនជនជាតិផ្សេងៗព្រមទាំងសម្តែងនូវក្តីជូនពរដ៏ល្អបវរចំពោះប្រជាជនទូទាំងប្រទេសចិនក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីចិននេះ។ ៥ ឆ្នាំមុនឯកឧត្តមធ្លាប់អញ្ជើញមកខេត្តយូនណានម្តង ។ ក្នុងអំឡុងពេល៥ឆ្នាំកន្លងទៅនោះ ខេត្តយូនណានបានកើតមានការផ្លាស់ប្តូរច្រើនគួរឱ្យកត់សម្គាល់ ។ កាសែតយើងខ្ញុំសូមចុះផ្សាយនូវអត្ថបទអំពីការផ្លាស់ប្តូរនៃខេត្តយូនណានក្នុងរយៈពេល៥ឆ្នាំកន្លងទៅដើម្បីបង្ហាញជូនលោកអ្នកអំពីការរីកចម្រើននៃខេត្តយូនណាន ។

នៅថ្ងៃទី១៩ ខែមករា ឆ្នាំ ២០២០ ឯកឧត្តមស៊ី ជីនភីង អញ្ជើញទៅទស្សនាក្រុមជនជាតិវ៉ាជុងចាយស៊ីម៉ូវ៉ា ភូមិសានចា ឃុំឈើងស្វយ ស្រុកធឹងឈុង ក្រុងប៉ាវសាន ដើម្បីសិក្សានិងយល់ដឹងពីស្ថានភាពនៃការស្តារនិងអភិវឌ្ឍន៍ភូមិជនជាតិភាគតិចនៅខេត្តយូនណាន។

ក្នុងភាសាជនជាតិវ៉ាពាក្យថា "ស៊ីម៉ូវ៉ា"មានន័យថា"កន្លែងប្រកបដោយសុភមង្គល"។ ភូមិនេះមានប្រវត្តិសាស្ត្រជាង៥០០ឆ្នាំហើយដែលជនជាតិវ៉ាហានប៉ៃ និងតៃជាដើម បានរួម រស់នៅជាមួយគ្នាដោយសុខដុមរមនា។ ប៉ុន្មានឆ្នាំមកនេះ រដ្ឋបាលភូមិខិតខំជំរុញ ការបង្កើតភូមិទេសចរណ៍ពិសេស អំពីវប្បធម៌ជនជាតិវ៉ាហើយកែលម្អលំនៅដ្ឋាន-រថយន្តសម្ព័ន្ធជាបន្តបន្ទាប់។ នៅឆ្នាំ២០១៩ អ្នកភូមិបានទទួលចំណូលជាមធ្យម១១.៥៤៨យ័នសម្រាប់មនុស្សម្នាក់ៗដែលបានធ្វើឱ្យអ្នកភូមិមានជីវភាពរស់នៅកាន់តែមានសុភមង្គល។

ជាការពិតក្នុងខេត្តយូនណាននៅមានភូមិដូចភូមិស៊ីម៉ូវ៉ាជាច្រើន។ ជនជាតិភាគតិចចំនួន២៥ បានរស់នៅក្នុងខេត្តយូនណានយូរមកហើយ។ នៅខេត្តយូនណានមានប្រជាជនជនជាតិភាគតិច១៥,៩លាននាក់ ស្មើនឹង១ភាគ៣នៃចំនួនប្រជាជនទូទាំងខេត្តយូនណាន។ ខេត្តយូនណានចាត់ទុកការអភិវឌ្ឍជា "កូនសោ" សម្រាប់ពង្រឹងសាមគ្គីភាពនិងជំរុញវិបុលភាពនៃជនជាតិផ្សេងៗ។ បច្ចុប្បន្នក្នុងស្រុក (ក្រុង) ស្វយ័តជនជាតិភាគតិចចំនួន៧៨ នៃខេត្តយូនណានមានស្រុក (ក្រុង) ស្វយ័តចំនួន៤៣ បានត្រូវតភ្ជាប់ដោយផ្លូវល្បឿនលឿន ហើយមានព្រលានយន្តហោះចំនួន៩ បានត្រូវសាងសង់នៅក្នុងតំបន់ជនជាតិភាគតិច។ ជាពិសេសមណ្ឌលស្វយ័តចំនួន ៤ រួមមានឈូស្យុងតាលី វិនសាន និងហុងហឺ បានបើកខ្សែរថភ្លើងល្បឿនលឿន។ កសិកម្មពិសេសនិងទេសចរណ៍-វប្បធម៌បានក្លាយទៅជានាមប័ណ្ណរបស់តំបន់ជនជាតិភាគតិច។ នៅចុងឆ្នាំ២០១៩ ប្រជាជនក្រីក្រនៅតំបន់ស្វយ័តជនជាតិភាគតិចនៃខេត្តយូនណានបានត្រូវកាត់បន្ថយដល់១៦,៥ម៉ឺននាក់៕ **(កាសែតយូនណានដេលី)**

## ខេត្តយូនណានចាត់វិធានការច្រើនដើម្បីជួយទេសចរនៅខេត្តយូនណាន

នៅថ្ងៃទី២៧ ខែមករា ឆ្នាំ ២០២០ មន្ទីរវប្បធម៌និងទេសចរណ៍ខេត្តយូនណានបានប្រកាសនូវ "លិខិតជូនដំណឹងឱ្យទេសចរមកពីខេត្តហ៊ូប៉េ" ថា ខេត្តយូនណាន នឹងប្រកាសព័ត៌មានអំពីលេខទូរស័ព្ទសួរព័ត៌មានសម្រាប់ទេសចរនៅស្រុក (ក្រុង/ខណ្ឌ) ចំនួន ១២៩ នៃខេត្តយូនណាន និង សណ្ឋាគារសម្រាប់ទេសចរស្នាក់ទៅ ដើម្បីជួយដោះស្រាយបញ្ហាប្រឈមរបស់ទេសចរនៅខេត្តយូនណានដែលមកពីខេត្តក្រុងផ្សេងៗ។

នៅថ្ងៃទី២៦ ខែមករា ឆ្នាំ ២០២០ ព័ត៌មានអំពីសណ្ឋាគារស្នាក់នៅ និងលេខទូរស័ព្ទនៃស្ថាប័នវប្បធម៌ និងទេសចរណ៍ខេត្តយូនណានសម្រាប់ផ្តល់សេវាកម្មដល់ទេសចរដែលមកពីតំបន់កើតជំងឺរលាកសួតប្រភេទថ្មីបានត្រូវប្រកាសជាសាធារណៈជាបន្តបន្ទាប់ ដើម្បីជួយដោះស្រាយបញ្ហាប្រឈមរបស់ទេសចរនៅខេត្តយូនណាន។ ក្រៅពីនេះ ទេសចរក៏អាចឆែកមើលព័ត៌មាន និងទិន្នន័យអំពីជំងឺរលាកសួតប្រភេទថ្មីតាមរយៈកម្មវិធី App "ដើរលេងខេត្តយូនណាន" និង "ដើរលេងខេត្តយូនណានដោយប្រើទូរស័ព្ទតែមួយគ្រឿង" ព្រមទាំងបទបញ្ជាដាក់កំហិតផ្នែកគមនាគមន៍ ព័ត៌មានស្វែងរកមនុស្សឈ្មោះមន្ទីរពេទ្យ សណ្ឋាគារស្នាក់នៅ និងលេខទូរស័ព្ទសួរព័ត៌មានសម្រាប់ទេសចរជាដើម៕

**ដោយលី ហ៊ុងឈាំង**

## ក្រុមសុខាភិបាលខេត្តយូនណានចេញដំណើរទៅកាន់ខេត្តហ៊ូប៉េ

នៅថ្ងៃទី២៧ ខែមករា ឆ្នាំ ២០២០ ពិធីជូនដំណើរក្រុមសុខាភិបាលខេត្តយូនណានទៅខេត្តហ៊ូប៉េបានរៀបចំនៅព្រលានយន្តហោះអន្តរជាតិឆាងស្វយ ក្រុងគុនមីង ។ ក្រុមសុខាភិបាលខេត្តយូនណាននេះមានសមាជិក១៣៧នាក់ ដែលមកពីមន្ទីរពេទ្យចំនួន៦ នៃខេត្តយូនណាន ។ ពួកគេប្រុងនឹងចេញដំណើរទៅកាន់ក្រុងអ៊ូហាននៃខេត្តហ៊ូប៉េ ដើម្បីចូលរួមការងារបង្ការគ្រប់គ្រង និងព្យាបាលជំងឺរលាកសួត ដែលបង្កដោយវីរុសកូរ៉ូណាប្រភេទថ្មី។

តាមការឱ្យដឹងរបស់តំណាងបានឱ្យដឹងថា នៅថ្ងៃទី២៦ ខែមករា សាលារដ្ឋបាលខេត្តយូនណាន បានប្រកាសសេចក្តីជូនដំណឹងជាបន្ទាន់អំពីការចាត់បញ្ជូនក្រុមសុខាភិបាលទៅខេត្តហ៊ូប៉េ។ គ្រូពេទ្យ និងគិលានុបដ្ឋាក គិលានុបដ្ឋាយិកាប់ពាន់នាក់នៅខេត្តយូនណានបានចុះឈ្មោះដោយស្ម័គ្រចិត្ត ដើម្បីទៅចូលរួមសកម្មភាពសង្គ្រោះបន្ទាន់នៅខេត្តហ៊ូប៉េ។ ក្រោយពីជ្រើសរើសដោយផ្ចិតផ្ចង់ខេត្តយូនណានបានបង្កើតក្រុមសុខាភិបាលទី១ ដើម្បីចាត់បញ្ជូនទៅកាន់ខេត្តហ៊ូប៉េ។ ក្រុមសុខាភិបាលនេះរួមមាន ក្រុមព្យាបាលអ្នកជំងឺធម្មតា ក្រុមសុខាភិបាលព្យាបាលអ្នកជំងឺធ្ងន់ធ្ងរ ក្រុមសុខាភិបាលពិនិត្យជំងឺ ក្រុមអ្នកថែទាំអ្នកជំងឺ ដែលមានគ្រូពេទ្យផ្នែកជំងឺដង្ហើម និងផ្នែកជំងឺធ្ងន់ធ្ងរជាដើម។ គួរបញ្ជាក់ថា សព្វថ្ងៃខេត្តយូនណានកំពុងរៀបចំក្រុមសុខាភិបាលទី២ ដើម្បីចាត់បញ្ជូនទៅកាន់ខេត្តហ៊ូប៉េ៕

**ដោយតឹន យីស៊ី និង ចាំង ធុង**




*ក្រុមសុខាភិបាលទី១ នៃខេត្តយូនណានចេញដំណើរទៅកាន់ខេត្តហ៊ូប៉េ*

## បង្ការនិងគ្រប់គ្រងជំងឺឆ្លងប្រទេសចិនកំពុងប្រតិបត្តិ

ពេលថ្មីៗនេះជំងឺរលាកសួតដែលបង្កដោយវីរុសកូរ៉ូណាប្រភេទថ្មីបានកើតឡើងក្នុងក្រុងអ៊ូហាន ខេត្តហ៊ូប៉េនិងខេត្តក្រុងមួយចំនួនទៀត ដែលបានទទួលនូវការចាប់អារម្មណ៍ពីសំណាក់ប្រជាជនចិនគ្រប់ៗគ្នា ។

ក្រោយពីកើតជំងឺឆ្លងប្រភេទថ្មីនេះប្រជាជនទូទាំងប្រទេសចិនតាំងពីរដ្ឋាភិបាលដល់រដ្ឋបាលមូលដ្ឋាន តាំងពីគ្រូពេទ្យដល់មហាជនសុទ្ធតែចាត់ទុកការយកឈ្នះជំងឺឆ្លងជាគោលដៅរួមរួមសាមគ្គីគ្នាជាធ្លុងមួយដើម្បីបង្កើតជាកម្លាំងរួមដ៏ខ្លាំងក្លាសម្រាប់បង្ការនិងគ្រប់គ្រងជំងឺឆ្លងប្រភេទថ្មីនេះ ។ នៅថ្ងៃទី ២៥ ខែមករា ឆ្នាំ២០២០ គណៈកម្មាធិការអចិន្ត្រៃយ៍នៃការិយាល័យនយោបាយមជ្ឈិមបក្សកុម្មុយនិស្តចិនបានរៀបចំកិច្ចប្រជុំដើម្បីស្តាប់ការរាយការណ៍អំពីការងារបង្ការនិងគ្រប់គ្រងជំងឺរលាកសួតដែលបង្កដោយវីរុសកូរ៉ូណាប្រភេទថ្មីហើយបានពិគ្រោះពិភាក្សាសិក្សាស្រាវជ្រាវ និងចាត់ចែងការងារម្តងទៀតអំពីការបង្ការនិងគ្រប់គ្រងជំងឺឆ្លងពិសេសគឺការព្យាបាលអ្នកជំងឺ ។ ឯកឧត្តម ស៊ី ជីនភីងអគ្គលេខាធិការមជ្ឈិមបក្សកុម្មុយនិស្តចិនបានសង្កត់ធ្ងន់ថា ជំងឺឆ្លងគឺជាបទបញ្ជាការងារបង្ការនិងគ្រប់គ្រងជំងឺឆ្លងគឺជាភារកិច្ច ។ ឱ្យតែមានជំនឿចិត្តរឹងមាំរួមសុខទុក្ខជាមួយគ្នាបង្ការនិងគ្រប់គ្រងជំងឺឆ្លងដោយប្រើវិធីវិទ្យាសាស្ត្រនិងចាត់វិធានការត្រឹមត្រូវយើងក៏អាចទទួលជ័យជម្នះក្នុងយុទ្ធនាការនៃការបង្ការនិងគ្រប់គ្រងជំងឺឆ្លងនេះ ។

បទបញ្ជាសំខាន់ៗមួយចំនួនធំកិច្ចប្រជុំស្តីពីការបង្ការនិងគ្រប់គ្រង ជំងឺឆ្លងជាច្រើនលើកនិងការប្រកាស ព័ត៌មានអំពីជំងឺឆ្លងឱ្យទាន់ពេលរបស់រដ្ឋាភិបាលចិនបានធ្វើឱ្យសាធារណជនកាន់តែមានជំនឿចិត្តនិងបានផ្សព្វផ្សាយពីចំណេះដឹងអំពីការបង្ការនិងគ្រប់ គ្រងជំងឺឆ្លង ហើយបានធ្វើឱ្យយុទ្ធនាការបង្ការ និងគ្រប់គ្រងជំងឺឆ្លងដំណើរការអនុវត្តដោយមានប្រសិទ្ធភាពខ្ពស់ក្នុងប្រទេសចិន ។

ប្រឈមនឹងជំងឺឆ្លងប្រភេទថ្មីនេះភាគីចិនកំពុងខិតខំធ្វើការសិក្សាស្រាវជ្រាវចាត់វិធានការទប់ទល់និងគ្រប់គ្រងជំងឺឆ្លង ។ ប្រជាជនចិនកំពុងយកចិត្តទុកដាក់និងពិនិត្យតាមដានស្ថានភាពជំងឺឆ្លងជារៀងរាល់ថ្ងៃតាមរយៈទូរស័ព្ទ និងទូរទស្សន៍ ។ ទិន្នន័យអំពីជំងឺឆ្លងកំពុងត្រូវផ្លាស់ជាថ្មីជារៀងរាល់ថ្ងៃដើម្បីបង្កើតជារបងដ៏រឹងមាំសម្រាប់គ្រប់គ្រងជំងឺឆ្លង ។ គ្រូពេទ្យក្លាហានកំពុងស្លៀកពាក់សម្លៀកបំពាក់ការពារជំងឺហើយខិតខំធ្វើការនៅចំពោះមុខអ្នកជំងឺដោយមិនចេះនឿយហត់។ នៅថ្ងៃទី ២៤ ខែមករាជាតិពុលនៃវីរុសកូរ៉ូណាប្រភេទថ្មីនេះបានត្រូវញែកដោយជោគជ័យ ។ បន្ទាប់មកអ្នកសិក្សាស្រាវជ្រាវបន្តខិតខំធ្វើការស្រាវជ្រាវអំពីវ៉ាក់សាំងការពារជំងឺឆ្លងប្រភេទថ្មីនេះទាំងយប់ទាំងថ្ងៃ ។ ក្រុមសុខាភិបាលនៃកងទ័ពរំដោះប្រជាជនចិន និងក្រុមសុខាភិបាលនៃតំបន់ផ្សេងៗ បានធ្វើដំណើរទៅកាន់ក្រុងអ៊ូហានជាបន្តបន្ទាប់ ។ មន្ទីរពេទ្យភ្នំទេវតាភ្លើងនិងមន្ទីរពេទ្យភ្នំទេវតារន្ទះកំពុងដំណើរការសាងសង់ដោយមានល្បឿនយ៉ាងលឿន ។ បុគ្គលិកការងារនៃសហគ្រាសផលិតសម្ភារពេទ្យក៏បានចូលធ្វើការមុនពេលកំណត់។ សប្បុរសជនទាំងក្នុងនិងក្រៅប្រទេសចិនបានផ្តល់ជំនួយឱ្យទាន់ពេល។ ជាពិសេសមានអ្នកជំងឺកាន់តែច្រើនត្រូវព្យាបាលឱ្យជាសះស្បើយហើយចេញពីមន្ទីរពេទ្យ ។ កម្លាំងរួមសាមគ្គីគ្នាដ៏ខ្លាំងក្លានិងរឹងមាំបាន និងកំពុងផុសឡើងនៅគ្រាអាសន្ននេះ ។

ជំងឺឆ្លងនេះក៏បានទទួលការចាប់អារម្មណ៍ពីសំណាក់ប្រជាជននៃបណ្តាប្រទេសនានាដែរ ។ យប់ថ្ងៃទី ៣០ ខែមករា ឆ្នាំ២០២០ លោក Tedros AdhanomGhebreyesus អគ្គនាយកនៃអង្គការសុខាភិបាលពិភពលោកបានរៀបចំសន្និសីទសារព័ត៌មាននៅក្រុងហ្សឺណែវហើយបានប្រកាសថា ជំងឺរលាកសួតដែលបង្កដោយវីរុសកូរ៉ូណាប្រភេទថ្មី បានក្លាយទៅជាព្រឹត្តិការណ៍សុខាភិបាលសាធារណៈដែលទទួលការចាប់អារម្មណ៍ពីបណ្តាប្រទេសនានាលើពិភពលោក ។ លោកបានសង្កត់ធ្ងន់ថា អង្គការសុខាភិបាលពិភពលោកមិនយល់ព្រមរហូតដល់ប្រឆាំងនឹងការដាក់បញ្ជាហាមឃាត់លើវិស័យទេសចរណ៍ ឬពាណិជ្ជកម្មចំពោះប្រទេសចិន។ លោកបានថ្លែងក្នុងសន្និសីទសារព័ត៌មាននេះថា ជារៀងរហូតមកភាគីចិនតែងតែប្រកាន់ខ្ជាប់នូវគោលការណ៍ដែលប្រកាសព័ត៌មានជាសាធារណៈ និងប្រកបដោយតម្លាភាពហើយបានប្រកាសនូវព័ត៌មានឱ្យទាន់ពេលសម្គាល់នូវធាតុហ្សែនវីរុសថ្មីនិងបានចាត់វិធានការដ៏មានប្រសិទ្ធភាពដើម្បីគ្រប់គ្រងជំងឺឆ្លង ។ នេះមិនគ្រាន់តែបានបញ្ជាំងឱ្យឃើញពីស្មារតីទំនួលខុសត្រូវកម្រិតខ្ពស់របស់ប្រទេសចិនចំពោះសុខភាពរបស់ប្រជាជននៃប្រទេសខ្លួនប៉ុណ្ណោះទេ ហើយក៏ជាការ ផ្តល់ការគាំទ្រយ៉ាងរឹងមាំដល់ការងារបង្ការ និងគ្រប់គ្រងជំងឺឆ្លងលើពិភពលោកទាំងមូលផងដែរ ។ លោកជឿ ជាក់ថា ភាគីចិននឹងគ្រប់គ្រងជំងឺឆ្លងដោយមានប្រសិទ្ធភាពនិងយកឈ្នះជំងឺ ឆ្លងនៅទីបញ្ចប់ ។ តាមពិតវិធានការ បង្ការនិងគ្រប់គ្រងជំងឺឆ្លងជាច្រើន របស់ប្រទេសចិនមានលំដាប់ខ្ពស់ជាងសំណូមពរពាក់ព័ន្ធសម្រាប់ដោះស្រាយភាពអាសន្នដែលបានបង្កើតជាគំរូថ្មីមួយសម្រាប់ការបង្ការជំងឺឆ្លងចំពោះប្រទេសផ្សេងៗ។

ឱ្យតែយើងទាំងអស់គ្នារួម សាមគ្គីគ្នាជាធ្លុងមួយក៏អាចឡើងលើ កំពូលភ្នំខ្ពស់ទាំងអស់។ ថ្ងៃនេះប្រជាជនទូទាំងប្រទេសចិននឹងរួមសាមគ្គីគ្នាជា ធ្លុងមួយដើម្បីទទួលជ័យជម្នះក្នុងយុទ្ធនាការនៃការបង្ការនិងគ្រប់គ្រងជំងឺរលាកសួតដែលបង្កដោយវីរុសកូរ៉ូណាប្រភេទថ្មី ៕



*ក្រោយពីកើតមានជំងឺឆ្លងភាគីនានាសុទ្ធតែផ្តល់ជំនួយ និងការគាំទ្រដល់ក្រុងអ៊ូហាន*